# ការចាប់ខ្លួន អៀង សារី និង អៀង ធីរិទ្ធ ជាជ័យជំនះមួយសម្រាប់កសិករកម្ពុជា

ប្រជាជនកម្ពុជាតែងតែនិយាយដល់របបកម្ពុជាប្រជាធិបតេយ្យដែលទទួលខុសត្រូវក្នុងការស្លាប់បាត់បង់ជីវិតមនុស្សអស់ជិតមួយភាគបួននៃប្រជាជនខ្មែរនៅអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ថាជាការទទួលខុសត្រូវរបស់ “បន ប៉ុល ពត អៀងសារី”។ មានមនុស្សមួយចំនួនតូចបានស្គាល់អំពីអត្តសញ្ញាណរបស់មេដឹកនាំសម្ងាត់របស់របបកម្ពុជាប្រជាធិបតេយ្យនៅក្រោយពេលដែលរបបនេះផុតរលត់ទៅ តែអ្នកទាំងនោះស្គាល់ អៀង សារី នៅពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៧០ ។ ដោយឈ្មោះគាត់នៅបន្ទាប់ពី ប៉ុល ពត (អ្នកទាំងពីរជាបងប្អូនថ្លៃ) ប្រជាជនកម្ពុជាស្គាល់ អៀង សារី យ៉ាងច្បាស់ថា ជាមេខ្លោងម្នាក់ក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍។

អៀង សារី ក្លាយជាជនកុម្មុយនិស្តក្លៀវក្លាម្នាក់ នៅខណៈពេលដែល ប៉ុល ពត កំពុងរៀននៅទីក្រុងប៉ារីសនៅទសវត្សរ៍ឆ្នាំ១៩៥០ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អៀង សារី មានតួនាទីជាឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេស ។ បន្ទាប់ពីបានរត់គេចខ្លួនទៅតំបន់ខ្មែរក្រហម នៅក្រុងប៉ៃលិនដែលពោរពេញទៅដោយត្បូង និងព្រៃឈើ នៅក្បែរព្រំដែនថៃនៅឆ្នាំ១៩៧៩ គាត់នៅតែមានតួនាទីខ្ពស់របស់ចលនាខ្មែរក្រហមរហូតដល់ឆ្នាំ១៩៨២ ទោះបីជាគាត់ត្រូវបានកាត់ទោសប្រហារជីវិតដោយកំបាំងមុខដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាក៏ដោយ ។ នៅឆ្នាំ១៩៩៦ គាត់ទទួលបាននូវការលើកលែងទោសមួយពីព្រះបាទនរោត្តម សីហនុ ទៅតាមសំណើរបស់សហនាយករដ្ឋមន្ត្រី ហ៊ុន សែន និង ព្រះអង្គម្ចាស់រណឫទ្ធិ ដើម្បីជាថ្នូរនិងការចុះចូលជាមួយរដ្ឋាភិបាល ដើម្បីទទួលបាននូវសន្តិភាព និងការផ្សះផ្សា ។

ភរិយារបស់លោក អៀង សារី ឈ្មោះ អៀង ធីរិទ្ធ ជាស្ត្រីម្នាក់ក្នុងចំណោមស្ត្រីមួយចំនួនតូច ដែលបានកាន់អំណាចនៅក្នុងរបបនេះ ។ អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីសង្គមកិច្ច និងជាប្រធានកាកបាទក្រហមនៅក្នុងរបបនេះ ។ គាត់ជាស្ត្រីមានសមត្ថភាពម្នាក់ចេញមកពីគ្រួសារអ្នកមាន ហើយបានជួប អៀង សារី នៅពេលដែលគាត់កំពុងសិក្សាពីល្ខោនសេកស្ពៀរ (Shakespeare) នៅសកលវិទ្យាល័យសូបូន (Sorbonne) ។ អៀង ធីរិទ្ធ បានបដិសេធមិនទទួលស្គាល់ថា គាត់ជាសមាជិករបស់គណៈមជ្ឈិម ដោយបាននិយាយថា គាត់គ្រាន់តែចង់បម្រើប្រទេសជាតិ និងប្រជាជន ហើយមិនដែល

ចង់បាន "មុននាទីខ្ពស់" ឡើយ ។ គាត់ក៏បានអះអាងផងដែរថា បើពុំមានការពេញចិត្តពីសំណាក់អ្នកដែលបានចូលរួមក្នុងចលនាបដិវត្តន៍នោះទេ ប្រទេសកម្ពុជាប្រហែលជាបាត់បង់ពីផែនទីពិភពលោក ។

អ្នកទាំងពីរនេះបានបដិសេធ ដូចជនដែលដល់ជាច្រើនទៀត ចំពោះការប្រព្រឹត្តខុស ហើយហាក់ដូចជាពុំមានការសោកស្តាយអ្វីសោះ ។ នៅឆ្នាំ១៩៩៩ អៀង ធីរិទ្ធ បានសរសេរទៅកាសែតភ្នំពេញ ដោយលើកសរសើរអ្នកទាំងឡាយណាដែលបានចេញពីផ្ទះស៊ីមស្ទោរបស់ខ្លួន ទៅរស់នៅក្នុងព្រៃនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ដើម្បីការពារមាតុប្រទេស ។ គាត់មិនដែលទទួលយកឥទ្ធិពលពីបដិវត្តន៍ម៉ៅ ដែលកសិករគួរតែជាអ្នកគ្រប់គ្រងប្រទេសនោះទេ ។

ប៉ុន្តែប្តីប្រពន្ធនេះ ដែលឋិតក្នុងវ័យ៧០ មិនធ្វើតាមខគ្គមគតិរបស់ខ្លួនទេ ផ្ទុយទៅវិញអ្នកទាំងពីរបានរើសយកការរស់នៅទាន់សម័យរបស់អ្នកដែលខ្លួនបានកោតសរសើរខាងលើនេះទៅវិញ ។ អ្នកទាំងពីរមានផ្ទះវីឡាមានតម្លៃមួយនៅទីក្រុងភ្នំពេញ ហើយតែងតែទៅពិនិត្យសុខភាពនៅទីក្រុងបាងកកប្រទេសថៃ ។ អ្នកទាំងពីរឥឡូវនេះជាអ្នកគោរពព្រះពុទ្ធសាសនាខ្ជាប់ខ្ជួន ហើយបានកសាង ចេតិយ៍មួយនៅវត្តជិតផ្ទះ ។ អ្នកទាំងពីរហាក់ដូចជាភ្លេចថា បក្សកុម្មុយនិស្តកម្ពុជា បានលុបបំបាត់ព្រះពុទ្ធសាសនា ដោយចាត់ទុកថា ជាសាសនា "ប្រតិកិរិយា" ដូចសាសនាផ្សេងទៀតដែរ ។

ប្រជាជនកម្ពុជាឆាប់មានប្រតិកម្មចំពោះអ្នកទាំងពីរ ដោយនិយាយថា ប្តីប្រពន្ធនេះឋិតនៅក្នុងចំណោមអ្នកបង្កើត "វាលពិឃាត"នៅប្រទេសកម្ពុជា អ្នកទាំងពីរបម្រើបដិវត្តន៍ដើម្បីយកតែឈ្មោះប៉ុណ្ណោះ ។ អ្នកទាំងពីរមានជីវិតសុខស្រួល និងមានឯកសិទ្ធិ តែប្រជាជនកម្ពុជាភាគច្រើននៅតែរកចំណូលបានតិចជាង ១ ដុល្លាក្នុងមួយថ្ងៃ ។ អ្នកក្រីក្រ ដែលឈ្មោះនេះបង្កើតឡើងដោយបដិវត្តន៍ហើយឥឡូវនេះប្រហែលជាក្រជាងពេលមុន និងនៅតែគ្មានអំណាចនោះ គឺដោយសារអ្នកទាំងពីរនេះឯង ។ ខ្មែរក្រហមបានបន្សល់ឲ្យយើងនូវសោកនាដកម្មធ្ងន់ធ្ងរមួយនៅឆ្នាំ១៩៧៩ ដោយសារតែប្រព័ន្ធអប់រំ សាសនា ធនាគារ ជំនួញ ទូរគមនាគមន៍ និងកសិកម្មត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង ។ មានប្រជាជនរស់រានជីវិតប្រហែលជា៧៥ភាគរយ ជាស្ត្រីមេម៉ាយ ដែលចាប់ផ្តើមកសាងជីវិតរបស់ខ្លួនឡើងវិញ ។

អៀង សារី, អៀង ធីរិទ្ធ, ប៉ុល ពត, នួន ជា, ខៀវ សំផន និងអ្នកផ្សេងទៀត បានធ្វើឲ្យប្រជាជនកម្ពុជាទាំងអស់ (លើកលែងតែក្រុមខ្លួន) ក្លាយជាកសិករនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជនទាំងអស់ត្រូវបានបង្ខំឲ្យធ្វើស្រែ និងកសាងប្រព័ន្ធធារាសាស្ត្រ តែផ្ទុយទៅវិញប្រជាជនជាច្រើនស្លាប់ដោយអត់អាហារ ឬក៏ស្លាប់ដោយធ្វើការហួសកម្លាំង ឬដោយជំងឺ ។ អៀង ធីរិទ្ធ បានទៅទស្សនាជាច្រើនដងនូវគម្រោងកសាងប្រព័ន្ធទឹកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយពិតជាបានឃើញ

*ពីលទ្ធផលរបស់នយោបាយរបបនោះ ។ បដិវត្តន៍អាចនឹងបាត់បង់ទៅ ប៉ុន្តែផលប៉ះពាល់នៅតែមានជាមួយយើងមកដល់សព្វថ្ងៃនេះ ។*

*ការចាប់ខ្លួន អៀង សារី និង អៀង ធីរិទ្ធ នៅថ្ងៃទី១២ខែវិច្ឆិកា ជាទីបញ្ចប់នេះនឹងផ្តល់នូវជ័យជំនះដល់ប្រជាជនសាមញ្ញ ។ ប្តីប្រពន្ធនេះ មានការផ្លាស់ប្តូរបន្តិចបន្តួច ហើយនៅតែមិនយល់ពីការឈឺចាប់របស់ជនរងគ្រោះ នឹងត្រូវនាំយកមកទទួលខុសត្រូវរឿងនេះ ហើយយើងទាំងអស់គ្នានឹងឃើញយុត្តិធម៌កើតមានឡើងនៅក្នុងតុលាការច្បាប់ ។ ការចាប់ខ្លួនមេដឹកនាំខ្មែរក្រហមដែលមិនអាចប៉ះពាល់បានដោយមូលហេតុនយោបាយ នឹងជាសារមួយដ៏មានឥទ្ធិពលដល់ប្រជាជនកម្ពុជា ហើយនិងផ្តល់ឲ្យយើងនូវក្តីសង្ឃឹមថា ប្រទេសយើងនិងធ្វើដំណើរឆ្ពោះទៅរកអនាគតល្អប្រសើរ ។*

**ឆាំង យុ**

**នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**

**ប្រែសម្រួលជាភាសាខ្មែរ ដោយ ព្រុំ ផល្លា**

**មជ្ឈមណ្ឌលឯកសារកម្ពុជា**